**រាជរដ្ឋាភិបាលកម្ពុជា**

**អនុក្រឹត្យ/៥៧.អនក្រ.បក/២៥ កញ្ញា ១៩៩៧/ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ

- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងបរិស្ថាន

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ១៩៩៧។

## សំរេច

## ជំពូក

## បទប្បញ្ញត្តិទូទៅ

**មាត្រា១:** អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងបរិស្ថាន និង កំណត់បេសកកម្មរបស់ក្រសួង និង មុខការនៃអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា។

## ជំពូក២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា២:** ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មអោយដឹកនាំ និង គ្រប់គ្រងវិស័យបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣:** ក្រសួងបរិស្ថានមានមុខងារ និង ភារកិច្ចដូចតទៅ:

- អនុវត្តនយោបាយបរិស្ថាន ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព និង ភាពស្ថិតស្ថេរ ព្រមទាំងរៀបចំសំណើស្តីពីផែនការបរិស្ថានជាតិ និង ផែនការបរិស្ថានតំបន់ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ។

- រៀបចំ និង អនុវត្តបរិធានច្បាប់បរិស្ថាននានាដើម្បីជំរុញ និង ធានាអោយមានការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព និង ភាពស្ថិតស្ថេរ ។

- អង្កេតពិនិត្យ និង ផ្តល់យោបល់លើការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង និង សកម្មភាពរបស់ឯកជន ឬ សាធារណៈដែលស្នើឡើងមានស្រាប់ និង កំពុងដំណើរការ ព្រមទាំងរៀបចំសំណើស្តីពីបែបបទនៃកិច្ចដំណើរការរៀបចំ និង ពិនិត្យឡើងវិញនូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

- ផ្តល់យោបល់ដល់ក្រសួងពាក់ព័ន្ធដើម្បីធានាការអភិរក្ស ការអភិវឌ្ឍន៏ និង ការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ រួមមាន ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្រ្ត ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និង ឧស្ម័ន ថ្ម និង ខ្សាច់ ត្បូងថ្ម ព្រៃឈើ និង អនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផលដោយសមហេតុសមផលប្រកបដោយនិរន្តរភាព និង ភាពស្ថិតស្ថេរ ។

- គ្រប់គ្រងតំបន់ការពារធម្មជាតិនានា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចមានចែងនៅក្នុង ព្រះរាជក្រឹត្យ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និង លើកសំណើស្តីពី ការបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត ។

- ចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពីប្រភព ប្រភេទ និង បរិមាណនៃសំណល់រឹង រាវ សារធាតុបំពុល សារធាតុពុល សារធាតុប្រកបដោយគ្រោះថ្នាក់ ផ្សែង សំលេង និង រំញ័រ ព្រមទាំងតាក់តែងវិធានការទប់ស្កាត់ កាត់បន្ថយ និង ត្រួតពិនិត្យការបំពុលបរិស្ថានដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

- រៀបចំនីតិវិធីនៃការធ្វើអធិការកិច្ចលើប្រភពបំពុល និង ការធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តការធ្វើអធិការកិច្ចលើប្រភពបំពុល និង ធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ។ អនុវត្តការផាកពិន័យអន្តរការណ៍ និង បទបញ្ញត្តិនានាដូចមានចែងក្នុង ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

- ប្រមូល វិភាគ និង គ្រប់គ្រងទិន្នន័យបរិស្ថាន និង រៀបចំចងក្រងរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ។ ផ្តល់ពតិមានស្តីពីសកម្មភាពរបស់ខ្លួន និង ពតិមានដែលទាក់ទង

ទៅនឹងកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ឬស្ថានភាពបរិស្ថានជូនសាធារណជន ព្រមទាំងលើកទឹកចិត្តអោយមានការចូលរួមពីសាធារណជនក្នុងកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

- តាក់តែង និង អនុវត្តកម្មវិធីអប់រំបរិស្ថានសំរាប់គ្រប់ស្រទាប់នៃសង្គម ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និង អន្តរជាតិ ។

- លើកសំណើជូនរាជរដ្ឋាភិបាលលើការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារអន្តរជាតិនានាស្តីពីកិច្ចការពារបរិស្ថាន ព្រមទាំងបំពេញកិច្ចការជំនាញពាក់ព័ន្ធសំរាប់ជាមូលដ្ឋានអោយរាជរដ្ឋាភិបាលបំពេញកាតព្វកិច្ច និង ការទទួលខុសត្រូវទាក់ទងនឹងកិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារអន្តរជាតិទាំងនោះ ។

- ជំរុញលើកទឹកចិត្តការវិនិយោគទុនក្នុងវិស័យការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ព្រមទាំងរៀបចំ និង គ្រប់គ្រងមូលនិធិទាយជ្ជទានបរិស្ថានសំរាប់កិច្ចការពារបរិស្ថាន និង ការអភិរក្សធនធានធម្មជាតិ ។

- សហការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និង បណ្តាប្រទេសនានា សំដៅធានាកិច្ចការពារបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤:** ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធដូចតទៅ:

ក. នៅថ្នាក់កណ្តាល

• អគ្គនាយកដ្ឋានបច្ចេកទេស:

- នាយកដ្ឋានផែនការ និង កិច្ចការច្បាប់

- នាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ

- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

- នាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យបរិស្ថាន

- នាយកដ្ឋានអប់រំ ពតិមាន និង ផ្សព្វផ្សាយបរិស្ថាន

- នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

• អធិការដ្ឋាន

• នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

• ខុទ្ទកាល័យរដ្ឋមន្ត្រី

ខ. អង្គភាពមូលដ្ឋាន

• មន្ទីរបរិស្ថានខេត្ត-ក្រុង។

## ជំពូក៣

## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា៥:** អគ្គនាយកដ្ឋានបច្ចេកទេសទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល គ្រប់គ្រងកិច្ចការផែនការ និង កិច្ចការច្បាប់ ការពារ និង អភិរក្សធម្មជាតិ ត្រួតពិនិត្យការបំពុលបរិស្ថាន វាយតំលៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យបរិស្ថាន អប់រំ ពតិមាន និង ផ្សព្វផ្សាយបរិស្ថាន និង អង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ អគ្គនាយកដ្ឋានបច្ចេកទេសដឹកនាំដោយអគ្គនាយកមួយរូប ដែលអមដោយអគ្គនាយករងជាជំនួយការ តាមការចាំបាច់។

អគ្គនាយកដ្ឋានបច្ចេកទេសមាននាយកដ្ឋានចំណុះចំនួន ៦ដូចតទៅ:

- នាយកដ្ឋានផែនការ និង កិច្ចការច្បាប់

- នាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ

- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

- នាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យបរិស្ថាន

- នាយកដ្ឋានអប់រំ ពតិមាន និង ផ្សព្វផ្សាយបរិស្ថាន

- នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា៦:** នាយកដ្ឋានផែនការ និង កិច្ចការច្បាប់មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញដើម្បីៈ

- រៀបចំពង្រាងបរិធានច្បាប់សំរាប់អនុវត្តច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

- សហការពិនិត្យឡើងវិញ និង ផ្តល់យោបល់លើការរៀបចំបរិធានច្បាប់នានាដោយស្ថាប័នផ្សេងៗដែលទាក់ទងនឹងបេសកកម្មរបស់ក្រសួង ។

- ផ្តល់យោបល់ទាក់ទងនឹងផ្នែកច្បាប់ជូនថ្នាក់ដឹកនាំក្រសួង និង នាយកដ្ឋានជំនាញស្តីពីការអនុវត្តសិទ្ធិអំណាចដែលមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

- រៀបចំគោលនយោបាយការពារបរិស្ថាន អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និង ភាពស្ថិតស្ថេរ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

- រៀបចំផែនការបរិស្ថានជាតិ ផែនការបរិស្ថានតំបន់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

- រៀបចំផែនការយុទ្ធសាស្ត្រ និង ផែនការការងារ ព្រមទាំងតាមដានវាយតំលៃលទ្ធផលការងាររបស់ក្រសួង ។

- សហការជាមួយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការលើកគំរោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ការបែងចែកថវិកាទាំងនោះតាមអង្គភាពចំណុះរបស់ក្រសួង និង ផ្តល់យោបល់ជូនឯកឧត្តមរដ្ឋមន្ត្រី ។

- សំរបសំរួលសកម្មភាព និង គំរោងជំនួយទ្វេភាគី និង ពហុភាគី ដែលផ្តល់អោយក្រសួងបរិស្ថានដើម្បីធានាអោយសកម្មភាព និង គំរោងទាំងនោះឆ្លើយតបចំទិសដៅ នយោបាយ និង អាទិភាពរបស់ក្រសួង។

- ធ្វើសហប្រតិបត្តិការអន្តរជាតិ។

- សំរបសំរួល និង គ្រប់គ្រងការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស និង ប្រចាំឆ្នាំរបស់នាយកដ្ឋាន និងមន្ទីរបរិស្ថានខេត្តទាំងអស់។

**មាត្រា៧:** នាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញដើម្បី:

- បំពេញកិច្ចការជំនាញពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារអន្តរជាតិនានាស្តីពីការអភិរក្សធម្មជាតិ និង តំបន់ការពារធម្មជាតិ។

- រៀបចំអនុវត្តគោលនយោបាយ និង ផែនការគ្រប់គ្រងឧទ្យានជាតិ ដែនជំរកសត្វព្រៃ តំបន់ការពារទេសភាព និង តំបន់ប្រើប្រាស់ច្រើនយ៉ាង ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យស្តីពី ការបង្កើតតំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលើកសំណើស្តីពីការ បង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត។

- សហការ ពិគ្រោះ និង ផ្តល់យោបល់ដល់ក្រសួងពាក់ព័ន្ធក្នុងកិច្ចការពារ និង អភិរក្សប្រព័ន្ធអេកូឡូស៊ីមានតំលៃដូចជា: តំបន់ដីសើម ទីជំរាល និង តំបន់ឆ្នេរ ដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និង នៅតំបន់ឯទៀតក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ។

- បំផុស និង ជំរុញអោយមានការចូលរួមពីសំណាក់សហគមន៍មូលដ្ឋាន សាធារណជនទូទៅស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា។

- រៀបចំ និងអនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានាសំរាប់កិច្ចការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

- អនុវត្តការផាកពិន័យអន្តរការណ៍ និងបទបញ្ញត្តិនានាដូចមានចែងក្នុង ជំពូកទី៩នៃ ច្បាប់ស្តីពី កិច្ចការពារ បរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៨:** នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញដើម្បី:

- បំពេញកិច្ចការជំនាញពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារអន្តរជាតិនានាស្តីពីកិច្ចការពារ គុណភាពបរិស្ថាន ។

- ចងក្រងបញ្ជីសារពើភ័ណ្ឌ ដែលបញ្ជាក់ពីប្រភព ប្រភេទ និង បរិមាណនៃសំណល់រឹង រាវ សារធាតុបំពុល សារធាតុពុល សារធាតុប្រកបដោយគ្រោះថ្នាក់ ផ្សែង សំលេង និង រំញ័រ ។

- រៀបចំ និង អនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានាសំរាប់កិច្ចការពារគុណភាពបរិស្ថាន និងត្រួតពិនិត្យការបំពុលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

- អង្កេតតាមដានធ្វើរបាយការណ៍ និង ផ្សព្វផ្សាយពីស្ថានភាពគុណភាពបរិស្ថាន រួមមានស្ថានភាពបំពុលខ្យល់ ទឹក ដី និង សំលេង ជូនសាធារណជន ។

- រៀបចំ សំណើស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចលើប្រភពបំពុល និង ការធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ច ។

- អនុវត្តការធ្វើអធិការកិច្ចលើប្រភពបំពុល និង ធ្វើរបាយការណ៍ស្តីពីបទល្មើសជូនស្ថាប័នមានសមត្ថកិច្ចដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

- អនុវត្តការផាកពិន័យអន្តរការណ៍ និង បទបញ្ញត្តិនានាដូចមានចែងក្នុង ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៩:** នាយកដ្ឋានវាយតំលៃធនធានធម្មជាតិ និង គ្រប់គ្រងទិន្នន័យបរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញ និង ស្ថាប័នពាក់ព័ន្ធដើម្បី:

- ប្រមែប្រមូល វិភាគ និង គ្រប់គ្រងទិន្នន័យស្តីពីធនធានធម្មជាតិ គុណភាពបរិស្ថាន និង សេដ្ឋកិច្ចសង្គម ដែលពាក់ព័ន្ធ ។

- កំណត់ស្ថានភាព និង និន្នាការផ្លាស់ប្តូរនៅក្នុងធនធានធម្មជាតិ គុណភាពបរិស្ថាន និង សេដ្ឋកិច្ចសង្គម ដែលពាក់ព័ន្ធ ។

- ផ្តល់ទិន្នន័យ និង ពត៌មានស្តីពីធនធានធម្មជាតិ ធនធានសេដ្ឋកិច្ចសង្គម និង គុណភាពបរិស្ថានដល់ នាយកដ្ឋានជំនាញ និង ស្ថាប័ននានាដែលពាក់ព័ន្ធ ។

- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីអំពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា និងរបាយការណ៍ផ្សេង ទៀតដែលចាំបាច់សំរាប់រាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ច និង ការទទួលខុសត្រូវដែលទាក់ទងនឹង កិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារអន្តរជាតិនានាស្តីពីកិច្ចការពារបរិស្ថាន ។

**មាត្រា១០:** នាយកដ្ឋានអប់រំ ពត៌មាន ផ្សព្វផ្សាយបរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋាន ជំនាញ និង ស្ថាប័នពាក់ព័ន្ធដើម្បីៈ

- តាក់តែង និង អនុវត្តកម្មវិធីអប់រំបរិស្ថានសំរាប់គ្រប់ស្រទាប់នៃសង្គម ។

- ចងក្រង និង ផ្សព្វផ្សាយពត៌មានស្តីពីបញ្ហាបរិស្ថាន ស្ថានភាពបរិស្ថាន និង សកម្មភាពការពារបរិស្ថាន នានា តាមរយៈបណ្តាញផ្សព្វផ្សាយ ការបោះពុម្ព ។ល ។

- ជំរុញការធ្វើសកម្មភាព និង យុទ្ធនានាការនានា សំដៅលើកទឹកចិត្តដល់សាធារណជនអោយចូលរួមក្នុង កិច្ចការពារគុណភាពបរិស្ថាន និង អភិរក្សធនធានធម្មជាតិ ។

- ផ្តួចផ្តើមគំនិត និង សំរបសំរួលវគ្គបណ្តុះបណ្តាលបរិស្ថាននានា ទាំងនៅក្នុងក្រសួងបរិស្ថាន ឬ ជាមួយ ក្រសួង និង ស្ថាប័នពាក់ព័ន្ធដទៃទៀត ។

- រៀបចំ និង អនុវត្តអនុក្រឹត្យ ព្រមទាំងបរិធានច្បាប់នានាសំរាប់ការចូលរួមរបស់សាធារណជន និង ការស្រង់យកពតិមាន ។

**មាត្រា១១:** នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មានភារកិច្ចសហការជាមួយនាយកដ្ឋានជំនាញ និង ស្ថាប័នពាក់ព័ន្ធដើម្បី:

- ពិនិត្យឡើងវិញលើការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង និងសកម្មភាពអភិវឌ្ឍន៍នានារបស់ឯកជន ឬ សាធារណៈ ដែលមានស្រាប់ និង កំពុងដំណើរការ និងផ្តល់យោបល់ទៅស្ថាប័នមានសមត្ថកិច្ច ។

- រៀបចំអនុក្រឹត្យស្តីពីបែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាល ។

- រៀបចំបញ្ជីដែលកំណត់ប្រភេទ ទំហំគំរោង និង សកម្មភាព ដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

- រៀបចំគោលការណ៍ណែនាំស្តីពីការធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

- ជំរុញអោយមានការចូលរួមពីសាធារណជនក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

- អង្កេតតាមដានការអនុវត្តគំរោង សំដៅកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអវិជ្ជមាន ។

## ជំពូក៤

## អធិការដ្ឋាន

**មាត្រា១២:** អធិការដ្ឋានរបស់ក្រសួងបរិស្ថានទទួលបន្ទុក:

- ធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ។

- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និង ពីមធ្យោបាយកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ ។

- ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ទុកចិត្ត។

អធិការដ្ឋានដឹកនាំដោយអធិការមួយរូប អមដោយអធិការរងជាជំនួយការ តាមការចាំបាច់។

## ជំពូក៥

## នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា១៣:** នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុក:

ក. ក្នុងវិស័យរដ្ឋបាលទូទៅ និង សរុប

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និង រវាងថ្នាក់កណ្តាល និង អង្គភាពមូលដ្ឋានក្រោមឱវាទ។

- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង។

- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល។

- សរុប និង ធ្វើរបាយការណ៏ការងារ និង សកម្មភាពផ្សេងៗរបស់ក្រសួង។

ខ. ក្នុងវិស័យគ្រប់គ្រងបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការក្រសួងដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

- រៀបចំលិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព។

- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង។

- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក។

- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និង បន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង អនុវត្តនយោបាយនោះ ។

- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និង តារាងពតិមានប្រតិបត្តិ ។

- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

គ. ក្នុងវិស័យគ្រប់គ្រងសំភារៈ និង បរិក្ខារ

- ប្រមូលផ្តុំតំរូវការធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និង បរិក្ខាររបស់ក្រសួង ។

- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និង ធ្វើបញ្ជីសារពើភ័ណ្ឌ ។

- គ្រប់គ្រងយានដ្ឋាន និង យានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និង គ្រឿងបន្លាស់ ។

- ទទួល និង បែងចែកបរិក្ខារជូនដល់បណ្តាអង្គការខេត្ត-ក្រុងនានា ។

- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និង គណនេយ្យរូបធាតុ ។

- ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

- ត្រួតពិនិត្យបច្ចេទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ឃ. ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ

- លើកគំរោងថវិកាក្រសួង និង តាមដានរំលឹកពីការប្រតិបត្តិ ។

- ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។

- ប្រមូលផ្តុំ និង សំរបសំរួលជំពូកថវិកា ។

- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។

- ប្រមូលផ្តុំ និង សំរបសំរួលរាល់ចំណាយរបស់ក្រសួង ។

- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

## ជំពូក៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា១៤:** ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកការងារទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

## ជំពូក៧

## អង្គភាពមូលដ្ឋាន

**មាត្រា១៥:** នៅតាមខេត្ត-ក្រុងនីមួយៗមានមន្ទីរបរិស្ថានខេត្ត-ក្រុង នៅតាមស្រុក-ខ័ណ្ឌមានភ្នាក់ងារ បរិស្ថានស្រុក-ខ័ណ្ឌ ។ មន្ទីរបរិស្ថានខេត្ត-ក្រុង និង ភ្នាក់ងារបរិស្ថានស្រុក-ខ័ណ្ឌ ទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូក៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា១៦:** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុង អនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក៩

## អវសានប្បញ្ញត្តិ

**មាត្រា១៧:** ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា១៨:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី និង រដ្ឋ - លេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា២០:** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| អ៊ឹង ហួត | ហ៊ុន សែន |

បានជំរាបជូន

- នាយករដ្ឋមន្ត្រីទី ១

- សម្តេចនាយករដ្ឋមន្ត្រីទី ២

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

បណ្ឌិត ម៉ុក ម៉ារ៉ែត

**អនុក្រឹត្យលេខ ៥៧ អនក្រ.បក**
**ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧**
**រចនាសម្ព័ន្ធក្រសួងបរិស្ថាន**

